# មេរៀនទី៦១៖ ព្រះយេស៊ូវបង្ហាញពីព្រះចេស្ដារបស់ទ្រង់

## ម៉ាកុស ១៖ ២១-២៨

**មេរៀនសម្រាប់គ្រូ** ( *យូធូបលីង* )៖ https://youtu.be/DZrWdZxaE0A

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/K2X080H6eZ0

**គោលបំណង៖** ព្រះយេស៊ូវគឺមានអំណាចព្រះចេស្ដាខ្លាំងណាស់

**ខគម្ពីរចងចាំ៖** ម៉ាថាយ ២៨៖១៨ *“ ឯព្រះយេស៊ូវ ទ្រង់យាងមកមានព្រះបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង ”។*

**ចំរៀង** ( *យូធូបលីង* )៖

១.ព្រះយេស៊ូវល្អក្រៃលែង https://youtu.be/uFsMi06lhvE

២.ព្រះយើងជាព្រះអស្ចារ្យ https://youtu.be/TU6HfxJXLvQ

៣.ព្រះអង្គទ្រង់អស្ចារ្យ https://youtu.be/QXEVqO94wpg

### ១. អធិស្ឋាន

### ២. ចំរៀង ( *រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស* )

### ៣. ល្បែងកំសាន្ត « តើអ្នកណាមានកម្លាំងខ្លាំងជាងគេ ?»



១.ចែកកុមារជា២ក្រុម

២.សូមឲ្យពួកគេលេងល្បែងទាញព្រ័ត្រ

៣.ពន្យល់កុមារថា មិនថាពួកគេគិតថាពួកគេខ្លាំងប៉ុណ្ណានោះទេតែក៏នៅមានមនុស្សម្នាក់ដែលមានអំណាចខ្លាំងជាងពួកគេដែរ។

### ៤. ការណែនាំមេរៀន

តើអ្នកគិតថាអ្នកណាខ្លះមានអំណាច ? តើឪពុកម្ដាយរបស់អ្នកមានអំណាចដែរឬទេ ? ចុះលោកគ្រូអ្នកគ្រូរបស់អ្នកវិញ ? ឬក៏នាយករដ្ឋមន្ត្រីយ៉ាងម៉េចដែរ ? ពេលមនុស្សមានអំណាចនិយាយ អ្នកឯទៀតតែងស្ដាប់តាម។ ពេលនាយករដ្ឋមន្ត្រីនិយាយ អ្នករាល់គ្នាស្ដាប់គាត់ព្រោះគាត់មានអំណាច។ ថ្ងៃនេះ យើងនឹងរៀនអំពីអំណាចរបស់ព្រះយេស៊ូវ ហើយសូម្បីតែវិញ្ញាណអារក្សក៏ស្ដាប់ទ្រង់ដែរ។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

ថ្ងៃមួយ ព្រះយេស៊ូវយាងទៅសាលាប្រជុំនៅក្រុងកាពើណិម ហើយចាប់ផ្ដើមបង្រៀន។ សាលាប្រជុំគឺជាព្រះវិហារមួយក្នុងសម័យព្រះយេស៊ូវ។ ប្រជាជនមានការងឿងឆ្ងល់ចំពោះការបង្រៀនរបស់ទ្រង់ ពីព្រោះព្រះអង្គបានបង្រៀនពួកគេដូចជា អ្នកដែលមានអំណាច។

នៅពេលនោះ មានបុរសម្នាក់ត្រូវបានអារក្សអសោចចូលនៅក្នុងសាលាប្រជុំ។ តើនេះស្តាប់ទៅគួរឱ្យខ្លាចដែរឬទេ? ប៉ុន្តែប្រសិនបើអ្នកជឿលើព្រះយេស៊ូវ នោះអ្នកមិនចាំបាច់ខ្វល់ខ្វាយអំពីការមានអារក្សចូលឡើយ ពីព្រោះនៅពេលដែលអ្នកទទួលយកព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់អ្នក នោះព្រះវិញ្ញាណបរិសុទ្ធនឹងមកគង់ក្នុងចិត្តរបស់អ្នក។ ព្រះវិញ្ញាណបរិសុទ្ធមានឥទ្ធិពលខ្លាំងណាស់ ដែលអារក្សមិនអាចចូលទៅក្នុងអ្នកបានឡើយ។

នៅពេលដែលបុរសត្រូវបានអារក្សចូលនោះឃើញព្រះយេស៊ូវក៏ស្រែកឡើងថា **ម៉ាកុស ១៖២៤** "ហ៊ឺះ តើយើងនឹងទ្រង់មានហេតុអ្វីនឹងគ្នា នែ ព្រះយេស៊ូវពីភូមិណាសារ៉ែតអើយ តើទ្រង់មកបំផ្លាញយើងឬអី ខ្ញុំស្គាល់ជាក់ហើយ ថាទ្រង់ជាព្រះអង្គបរិសុទ្ធនៃព្រះ!" ។វាពិតជាមានសារៈសំខាន់ណាស់ក្នុងការយល់ថាពួកអារក្សបានទទួលស្គាល់ព្រះយេស៊ូវថាជា "ព្រះដ៏បរិសុទ្ធនៃព្រះ" ។ សូម្បីតែនៅពេលខ្លះមនុស្សមិនបាន ទទួលយកព្រះយេស៊ូវជាព្រះរាជបុត្រាបរិសុទ្ធរបស់ព្រះក៏ដោយ ក៏អារក្សដឹងថាទ្រង់ជានរណា! ហើយ អារក្សក៏បានកោតខ្លាចព្រះយេស៊ូវដែរ!

នៅក្នុងព្រះគម្ពីរ **ម៉ាកុស ១៖២៥-២៦** បាននិយាយថា "ព្រះយេស៊ូវ ទ្រង់ក៏បន្ទោសដល់វាថា ចូរស្ងៀមទៅ ហើយថយពីមនុស្សនេះចេញ កាលអារក្សអសោចបានជាន់មនុស្សនោះឲ្យប្រកាច់ប្រកិនជាខ្លាំង ហើយស្រែកឡើង នោះវាក៏ចេញទៅ" ។ ព្រះយេស៊ូវមានអំណាច និងព្រះចេស្តាខ្លាំងណាស់ សូម្បីតែអារក្សក៏គោរពតាមបញ្ជារបស់ទ្រង់ដែរ! គ្រប់គ្នាដែលបានឃើញការនេះមានការងឿងឆ្ងល់ថា បុរសដែលមានអំណាចនេះជានរណា។

យើងដឹងថាទ្រង់ជាអ្នកណា! ទ្រង់គឺជាព្រះយេស៊ូវគ្រីស្ទជាព្រះរាជបុត្រានៃព្រះ! ព្រះយេស៊ូវមានឫទ្ធានុភាព ហើយអ្នកអាចទុកចិត្តបានថា ព្រះយេស៊ូវនឹងការពារអ្នក ហើយថែរក្សាអ្នកបានល្អ នៅពេលដែលអ្នកជឿលើអំណាចព្រះចេស្តារបស់ទ្រង់!

## ៦. សំនួរពិភាក្សា

១. តើព្រះយេស៊ូវបានទៅបង្រៀននៅឯណា? *(សាលាប្រជុំ)*

២. តើមនុស្សមានប្រតិកម្មយ៉ាងដូចម្តេចចំពោះការបង្រៀនរបស់ព្រះយេស៊ូវ? *(ពួកគេមានការភ្ញាក់ផ្អើល)*

៣. តើព្រះយេស៊ូវមានបន្ទូលយ៉ាងណាទៅកាន់អារក្សដែលបានចូលបុរសម្នាក់នោះ? *(គាត់ឲ្យអារក្សចេញទៅ)*

៤. តើមានអ្វីកើតឡើងចំពោះអារក្ស? *(វាបានស្តាប់បង្គាប់ព្រះយេស៊ូវ ហើយចេញទៅ)*

៥. តើអ្នកណាខ្លាំងជាងគេលើពិភពលោកយើងនេះ? *(ព្រះយេស៊ូវគ្រីស្ទ)*

## ៧. ល្បែងកំសាន្ត «អរគុណព្រះយេស៊ូវចំពោះមិត្តភក្តិរបស់ខ្ញុំ»



១. ល្បែងនេះយើងលេងដោយ ឲ្យកុមារអង្គុយជារង្វង់

២. យើងរើសកុមារម្នាក់មកដឹកនាំ គាត់ស្រែកនាំមុខថា អរគុណព្រះចំពោះកុមារណា ដែលមានអាវពណ៌ក្រហម(កុមារណាដែល មានអាវពណ៌ក្រហមត្រូវរត់ដូរកន្លែងគ្នា)

៣. កុមារណាចាញ់គាត់ជាអ្នកស្រែកនាំមុខម្តង។ អរគុណព្រះចំពោះ កុមារណាដែលមានជើងពីរ កុមារណាដែលមានសក់វែង ។ល។

## ៨. ខគម្ពីរចងចាំ

**ម៉ាថាយ ២៨៖១៨** *"ឯព្រះយេស៊ូវ ទ្រង់យាងមកមានព្រះបន្ទូលនឹងគេថា គ្រប់ទាំងអំណាចបានប្រគល់មកខ្ញុំនៅលើស្ថានសួគ៌ ហើយលើផែនដីផង"* ។

## ៩. ហាត្ថកម្ម

សូមផាត់ពណ៌ "ព្រះយេស៊ូវបានបណ្តេញវិញ្ញាណអារក្សចេញ។"

## ១០. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

## ១១. អធិស្ឋាន

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
ថ្ងៃនេះ យើងនឹងរៀនអំពីអំណាចរបស់ព្រះយេស៊ូវ។ ទ្រង់មានអំណាចខ្លាំងណាស់ សូម្បីតែអារក្សក៏ស្តាប់បង្គាប់ព្រះអង្គដែរ។ តើផ្នែកណាខ្លះក្នុងជីវិតរបស់អ្នក ដែលអ្នកត្រូវស្តាប់បង្គាប់ព្រះ ? ចូរអធិស្ឋានដើម្បីឲ្យអ្នកអាចទទួលបទពិសោធន៍ពីព្រះចេស្តានៃព្រះយេស៊ូវនៅក្នុងជីវិតរបស់អ្នក នៅពេលអ្នកស្តាប់បង្គាប់ទ្រង់ ។


ព្រះយេស៊ូវបានបណ្ដេញវិញ្ញាណអារក្សចេញ
ម៉ាកុស១:២៥
"ព្រះយេស៊ូវ ទ្រង់ក៏បន្ទោសដល់វាថា ចូរស្ងៀមទៅ ហើយ
ថយពីមនុស្សនេះចេញ។"